ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន
ចូល
លេខ ៧៩៦
ថ្ងៃទី ០៦ ខែ ១២ ឆ្នាំ ២០១១
ម៉ោង ១០:០០

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ២៦៩៧ អយក.ហ៊ីសាលា

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១១

## សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ទៅសិក្សានៅសាធារណរដ្ឋឆែកក្នុងឆ្នាំសិក្សា២០១២-២០១៣

**យោង** : លិខិតលេខ No.:1395/2011-BANG ចុះថ្ងៃទី 0៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ស្ថានទូតសាធារណរដ្ឋឆែកនៅព្រះរាជាណាចក្រថៃ

### ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងដល់សាធារណជនទាំងពីរភេទថា សម្រាប់ឆ្នាំសិក្សា ២០១២-២០១៣ នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋឆែកនឹងផ្តល់អាហារូបករណ៍ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់** (Master's Degree) រឺថ្នាក់ **បរិញ្ញាបត្រ** (Bachelor's Degree) ចំនួន ០២កន្លែង ដល់និស្សិតកម្ពុជាដើម្បីទៅសិក្សានៅសាធារណរដ្ឋឆែក ។

រដ្ឋាភិបាលឆែក ជាអ្នកផ្តល់អាហារូបករណ៍ និងរ៉ាប់រងថ្លៃសាលា ។ និស្សិតត្រូវមានប្រាក់សម្រាប់ចំណាយខ្លួនឯងបន្ថែមទៀត ។ ឯសំបុត្រយន្តហោះទៅមកជាបន្ទុករបស់សាមីជន ។

**I-លក្ខខណ្ឌកំណត់នៃការជ្រើសរើស**

**១-ថ្នាក់បរិញ្ញាបត្រ**

**បេក្ខជនទាំងពីរភេទត្រូវ :**

- មានសញ្ជាតិកម្ពុជា
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

**២-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**បេក្ខជនទាំងពីរភេទត្រូវ :**

- មានសញ្ជាតិកម្ពុជា

- មានសញ្ញាបត្របរិញ្ញាបត្រ (**Bachelor**)
- មានសុខភាពល្អបរិបូរណ៏ទាំងកាយសម្បទា និងសតិបញ្ញា

**+ សំណុំឯកសារដែលត្រូវបំពេញ និងជូនភ្ជាប់ :**

- Application form in English
- សញ្ញាបត្រ-ព្រឹត្តិបត្រពិន្ទុ និងសំបុត្រកំណើត ត្រូវបកប្រែជាភាសាឆែក និងបញ្ជាក់ដោយស្ថានបេសកកម្មនៃសាធារណរដ្ឋឆែក

**II-មុខវិជ្ជាទៅសិក្សាស្រាវជ្រាវមាន :**

- Agriculture, Forestry, Technical Studies, Economy, and Medical Science

**III-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ :**

បេក្ខជនដែលមានបំណងចូលរួមក្នុងកម្មវិធីនេះត្រូវមកទាក់ទងរកពាក្យសុំអាហារូបករណ៍ និងបំពេញសំណុំបែបបទផ្សេងៗនៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាស័យដ្ឋានអគារលេខ ៨០ មហាវិថីព្រះនរោត្តម (ស្ថិតក្នុងទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា) ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី **២៦** ខែ **ធ្នូ** ឆ្នាំ **២០១១** ។

ចំពោះព័ត៌មានលម្អិត សូមទាក់ទងផ្ទាល់ជាមួយការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍តាមអាស័យដ្ឋានខាងលើ ។

**ត.ប រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយក**

**ស៊ើ_សុជាតា**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

"*ដើម្បីជូនជ្រាបជាព័ត៌មាន*"

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

-គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

"*ដើម្បីជួយផ្សព្វផ្សាយ និងឧទ្ទេសនាមបេក្ខជន*"

-កាលប្បវត្តិ-ឯកសារ ន.ទវអ